# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

របាយការណ៍ហិរញ្ញវត្ថុ
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011
និង
របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 1413/02E |
| ទីស្នាក់ការ | ផ្ទះលេខ 94 ផ្លូវ 360 សង្កាត់ បឹងកេងកង 3<br>ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ម្ចាស់ភាគហ៊ុន | DWM Funds S.C.A.-SICAV SIF<br>TPC-ESOP Co., Ltd. |
| ក្រុមប្រឹក្សាភិបាល | លោក Michael John Spingler ប្រធាន<br>លោកស្រី Fernanda Pecanha Lacerda De Lima<br>លោក Ry Vanna (លាលែងនៅថ្ងៃទី 10 ខែ មេសា ឆ្នាំ 2011)<br>លោកស្រី Jessica Moffett-Rose (តែងតាំងនៅថ្ងៃទី11 ខែ កុម្ភៈ ឆ្នាំ 2011)<br>លោក Chandula P.Abeywickrema<br>លោក Christophe Forsinetti (តែងតាំងនៅថ្ងៃទី11 ខែ កុម្ភៈ ឆ្នាំ 2011) |
| គណៈគ្រប់គ្រង | លោកស្រី Nurhayrah Sadava ប្រធាននាយិកាប្រតិបត្តិ<br>(តែងតាំងនៅថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2011)<br>លោក Michael John Spingler ប្រធាននាយកប្រតិបត្តិស្តីទី<br>(លាលែងនៅថ្ងៃទី 30 ខែ កញ្ញា ឆ្នាំ 2011)<br>លោក ជួន សុផល ប្រធាននាយកប្រតិបត្តិ<br>(ចូលនិវត្តន៍នៅថ្ងៃទី 31 ខែ មករា ឆ្នាំ 2011)<br>លោក សុខ វឿន ប្រធាននាយកប្រតិបត្តិការ<br>លោក សុខ សុផល ប្រធាននាយកហិរញ្ញវត្ថុ |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ |

**ធនាគារភូមិ (ខេមបូឌា) អិលធីឌី**

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2. | របាយការណ៍របស់សវនករឯករាជ្យ | 6 |
| 3. | តារាងតុល្យការ | 8 |
| 4. | របាយការណ៍លទ្ធផល | 9 |
| 5. | របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន | 10 |
| 6. | របាយការណ៍ចលនាសាច់ប្រាក់ | 11 |
| 7. | កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 13 |

TPC

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ធ្វើការដាក់ជូននិនិត្យនូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន" រឺ "TPC") ដែលបានធ្វើសវនកម្មរួច សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដល់ប្រជាជននៅជនបទនៃប្រទេសកម្ពុជា តាមរយៈទីស្នាក់ការកណ្តាលនៅភ្នំពេញ និងទីស្នាក់ការតាមបណ្តាខេត្តនានានៅក្នុងប្រទេសកម្ពុជា ។ គោលដៅរបស់ក្រុមហ៊ុន គឺត្រូវផ្តល់សេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងដែលអាចទទួលយកបាន ដល់សហគ្រិនខ្នាតតូចនៅតាមជនបទ និង បរិវេណជុំវិញទីក្រុងភ្នំពេញ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 មានដូចខាងក្រោម:

| | ពាន់រៀល |
|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 7,420,847 |
| ពន្ធលើប្រាក់ចំណេញ | (1,529,166) |
| ប្រាក់ចំណេញសំរាប់ការិយបរិច្ឆេទ | 5,891,681 |

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវ័ន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថា វិធានការទាំងឡាយដែលទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសំរាប់ឥណទានអាក្រក់ និង ជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានលក្ខណៈមិនគ្រប់គ្រាន់ រហូតដល់កំរិតជាសារវ័ន្តណាមួយនោះទេ ។

E-mail : tpcho@tpc.com.kh
Tel: (855) 23 220 641 - Fax : (855) 23 220 642
#94, Street 360, Sangkat Boeung Keng Kang III,
Khan Chamkarmon, Phnom Penh, Cambodia

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ភាគលាភ

នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រុមហ៊ុនបានប្រកាស និងបង់ភាគលាភចំនួន 349 លានរៀល ដោយដកចេញពីប្រាក់ចំណេញរក្សាទុកពីការិយបរិច្ឆេទមុន ។

### ដើមទុន

នៅថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2011 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនរបស់ខ្លួនដល់ចំនួន 6,176,400 ពាន់រៀល ដោយដាក់ដើមទុនបន្ថែមចំនួន 2,176,400 ពាន់រៀលពី DWM Funds S.C.A.-SICAV SIF និង TPC-ESOP Co., Ltd ។ ធនាគារជាតិនៃកម្ពុជាបានអនុម័តលើការបង្កើនដើមទុននេះតាមរយៈលិខិតចុះថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 2011 ។

រចនាសម្ព័ន្ធដើមទុន និងសេចក្តីលំអិតអំពីភាគហ៊ុនដែលបានបោះផ្សាយ និងចុះបញ្ជីមានដូចខាងក្រោម:

| | ← 2011 | | → | ← 2010 | | → |
|---|---|---|---|---|---|---|
| | ភាគរយម្ចាស់ហ៊ុន | ចំនួនហ៊ុន | ចំនួនពាន់រៀល | ភាគរយម្ចាស់ហ៊ុន | ចំនួនហ៊ុន | ចំនួនពាន់រៀល |
| DWM Funds S.C.A. -SICAV SIF | 89.82 | 55,474 | 5,547,400 | 87.84 | 35,134 | 3,513,400 |
| TPC-ESOP Co., Ltd | 10.18 | 6,290 | 629,000 | 12.16 | 4,866 | 486,600 |
| | 100 | 61,764 | 6,176,400 | 100 | 40,000 | 4,000,000 |

ភាគហ៊ុនដែលបានចុះបញ្ជី បោះផ្សាយ និងបង់រួចរាល់សរុបទាំងអស់មានចំនួន 61,764 ហ៊ុន (31 ខែ ធ្នូ ឆ្នាំ 2010: 40,000 ហ៊ុន) ដែលមានតម្លៃចារឹក 100,000 រៀល ក្នុងមួយហ៊ុន (31 ខែ ធ្នូ ឆ្នាំ 2010: 100,000 រៀល).

ការកែតម្រូវអនុស្សារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 7 ខែ មីនា ឆ្នាំ 2012 ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្ត ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលមានតម្លៃមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ ។

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្រ្ត ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមាន:

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាលពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទដែលនឹងអាចមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវ័ន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

### ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាលលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទមិនមានការប៉ះពាល់ណាមួយដល់ចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានយោបល់ដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវ័ន្តនិង មិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

### ព្រឹត្តការណ៍ចាប់ពីថ្ងៃធ្វើរបាយការណ៍

ពុំមានព្រឹត្តិការណ៍សំខាន់ៗ កើតមានឡើងនៅក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ ដែលតម្រូវឲ្យមានការបង្ហាញ ឬការធ្វើនិយ័តកម្មនោះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទនិងថ្ងៃចេញរបាយការណ៍នេះមាន៖

| | |
|---|---|
| • លោក Michael John Spingler | ប្រធានក្រុមប្រឹក្សាភិបាល |
| • លោកស្រី Fernanda Pecanha Lacerda De Lima | អភិបាល |
| • លោក Ry Vanna | អភិបាល (លាលែងនៅថ្ងៃទី 10 ខែ មេសា ឆ្នាំ 2011) |
| • លោកស្រី Jessica Moffett-Rose | អភិបាល (តែងតាំងនៅថ្ងៃទី11 ខែ កុម្ភៈ ឆ្នាំ 2011) |
| • លោក Chandula P.Abeywickrema | អភិបាល |
| • លោក Christophe Forsinetti | អភិបាល (តែងតាំងនៅថ្ងៃទី11 ខែ កុម្ភៈ ឆ្នាំ 2011) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកណាម្នាក់កាន់កាប់ ឬមានជាប់ទាក់ទិនផ្ទាល់នៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុននោះទេ ។ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគី ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុនពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀត។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងថ្ងៃបញ្ចប់ការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយនៃការទិញយកភាគហ៊ុន ឬលិខិតបំណុល ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅអំពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងចំនួនបរិលាភសរុបទទួលបានដោយសមាជិកក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធណាមួយជាមួយនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលជាសមាជិក ឬ ក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ បានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 និងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពចលនាសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

(ក) អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្នហើយធ្វើការអនុវត្តន៍ឱ្យបានជាប់លាប់ ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ខ) អនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជានិង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬបើមានការផ្លាស់ប្តូរពីនេះត្រូវធ្វើការកំណត់បង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ ហើយកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព ។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគតដែលគិតទុកជាមុន ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសំរេចដែលមានសារៈសំខាន់ទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការ ហើយត្រូវធ្វើឱ្យប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាបានអនុវត្តនូវរាល់តម្រូវការខាងលើដូចមានរាយការណ៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល:*

ព្រះរាជាណាចក្រកម្ពុជា
ធនាគារភូមិ (ខេមបូឌា) អិលធីឌី
THANEAKEA PHUM (CAMBODIA) LTD.

______________________

លោក Christophe Forsinetti

*អភិបាល*

ថ្ងៃទី 29 MAR 2012

KPMG

KPMG Cambodia Ltd
4th floor, Delano Center
No. 144, Street 169
Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះម្ចាស់ភាគហ៊ុន
## ធនាគារភូមិ (ខេមបូឌា) អិលធីឌី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2011 និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សំគាល់ ដែលរួមមានសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី 8 ដល់ 58 ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំនិងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលគណៈគ្រប់គ្រងបានកំណត់ថាមានភាពចាំបាច់សំរាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អោយជៀសផុតពីកំហុសឆ្គងជាសារវន្តបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនេះតម្រូវឱ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ ដោយគ្រោងនិងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានិតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនិតិវិធីទាំងនេះ គឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យដែលមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះយើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើសវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណង ដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។



KPMG Cambodia Ltd., a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity. All rights reserved.

KPMG

## ការទទួលខុសត្រូវរបស់សវនករ (ត)

ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលការណ៍គណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រងព្រមទាំងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសំរាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិយោបល់

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ធនាគារភូមិ (ខេមបូឌា) អិលធីឌី** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពចលនាសាច់ប្រាក់របស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

Craig McDonald
*Audit Partner*

រាជធានីភ្នំពេញ

ថ្ងៃទី 29 ខែ មីនា ឆ្នាំ 2012

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | កំណត់សំគាល់ | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 474,214 | 322,678 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារនានា | 5 | 45,292,288 | 34,946,852 |
| ប្រាក់បញ្ញើតាមច្បាប់ | 6 | 324,020 | 215,200 |
| ឥណទានផ្តល់ដល់អតិថិជន | 7 | 133,743,863 | 88,459,910 |
| គណនីត្រូវទទួលផ្សេងទៀត | 8 | 3,874,124 | 2,364,604 |
| អចលនទ្រព្យ និងទ្រព្យសម្ភារ | 9 | 1,532,569 | 1,199,820 |
| ទ្រព្យសកម្មអរូបិយ | 10 | 7,409 | 14,819 |
| វិនិយោគរយៈពេលវែង | 11 | 60,585 | - |
| ពន្ធពន្យារជាទ្រព្យសកម្ម | 12 | 250,362 | 139,639 |
| **សរុបទ្រព្យសកម្ម** | | 185,559,434 | 127,663,522 |
| **បំណុល និងមូលនិធិម្ចាស់ហ៊ុន** | | | |
| **បំណុល** | | | |
| ប្រាក់បញ្ញើពីអតិថិជន | 13 | 292,456 | 394,981 |
| ប្រាក់កម្ចី | 14 | 147,713,373 | 99,081,495 |
| បំណុលផ្សេងៗ | 15 | 3,664,036 | 2,705,933 |
| ជំនួយពន្យា | | 12,224 | 16,298 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | 12 | 1,311,518 | 618,069 |
| **សរុបបំណុល** | | 152,993,607 | 102,816,776 |
| **មូលនិធិម្ចាស់ហ៊ុន** | | | |
| ដើមទុន | 16 | 6,176,400 | 4,000,000 |
| ទុនបំរុង | | 1,955,663 | 1,373,211 |
| ប្រាក់ចំណេញរក្សាទុក | | 24,433,764 | 19,473,535 |
| **សរុបមូលនិធិម្ចាស់ហ៊ុន** | | 32,565,827 | 24,846,746 |
| **សរុបបំណុលនិងមូលនិធិម្ចាស់ហ៊ុន** | | 185,559,434 | 127,663,522 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍លទ្ធផល
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | កំណត់សំគាល់ | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|---|
| ចំណូលពីការប្រាក់ | 17 | 35,538,246 | 26,546,534 |
| ចំណាយលើការប្រាក់ | 18 | (11,365,283) | (9,396,460) |
| **ចំណូលសុទ្ធពីការប្រាក់** | | 24,172,963 | 17,150,074 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 19 | 504,032 | 326,587 |
| **ចំណូលប្រតិបត្តិការ** | | 24,676,995 | 17,476,661 |
| ចំណាយកំរៃជើងសារ | 20 | (426,796) | (475,559) |
| ចំណាយផ្នែកបុគ្គលិក | 21 | (11,222,570) | (8,665,513) |
| ចំណាយរំលស់ | | (693,264) | (591,344) |
| ចំណាយរដ្ឋបាល | 22 | (4,977,612) | (3,736,556) |
| ដកចេញសំវិធានធនសំរាប់ឥណទានអាក្រក់ និង ជាប់សង្ស័យ | | 60,019 | 378,277 |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | | 7,416,772 | 4,385,966 |
| ចំណូលបានពីជំនួយ | | 4,075 | 10,328 |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 7,420,847 | 4,396,294 |
| ពន្ធលើប្រាក់ចំណេញ | 12 | (1,529,166) | (906,427) |
| **ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ** | | 5,891,681 | 3,489,867 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | ដើមទុន<br>ពាន់រៀល | ទុនបំរុង<br>ពាន់រៀល | ប្រាក់ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 4,000,000 | 788,740 | 16,568,139 | 21,356,879 |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបំរុង | - | 584,471 | (584,471) | - |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | 3,489,867 | 3,489,867 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 4,000,000 | 1,373,211 | 19,473,535 | 24,846,746 |
| ដើមទុនបន្ថែមពីការបោះផ្សាយភាគហ៊ុន | 2,176,400 | - | - | 2,176,400 |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបំរុង | - | 582,452 | (582,452) | - |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | 5,891,681 | 5,891,681 |
| ភាគលាភបានទូទាត់ | - | - | (349,000) | (349,000) |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 | 6,176,400 | 1,955,663 | 24,433,764 | 32,565,827 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | 7,420,847 | 4,396,294 |
| និយ័តកម្មលើចំណូលនិងចំណាយមិនមែនសាច់ប្រាក់: | | |
| រំលស់ | 693,264 | 591,344 |
| ប្រាក់ជំនួយ | (4,075) | (10,328) |
| ដកចេញសំវិធានធនលើឥណទានអាក្រក់និងជាប់សង្ស័យ | (60,019) | (378,277) |
| | 8,050,017 | 4,599,033 |
| ការប្រែប្រួលនៃ: | | |
| ប្រាក់បញ្ញើនិងតម្កល់នៅធនាគារនានា | (4,450,932) | 3,280,236 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | (108,820) | - |
| ឥណទានផ្តល់ដល់អតិថិជន | (45,223,934) | (19,207,734) |
| គណនីត្រូវទទួលផ្សេងៗ | (1,509,520) | (655,912) |
| ប្រាក់បញ្ញើពីអតិថិជន | (102,525) | (27,611) |
| បំណុលផ្សេងៗ | 958,103 | 647,993 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (42,387,611) | (11,363,995) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (946,440) | (399,192) |
| ប្រាក់ជំនួយទទួលបាន | - | 4,895 |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (43,334,051) | (11,758,292) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | |
| ការទិញអចលនទ្រព្យ និងទ្រព្យសម្ភារ | (1,018,603) | (753,390) |
| ការវិនិយោគ | (60,585) | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ | (1,079,188) | (753,390) |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ចលនាសាច់ប្រាក់ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 111,246,435 | 71,142,366 |
| ការទូទាត់សងប្រាក់កម្ចី | (62,614,556) | (65,114,563) |
| សាច់ប្រាក់ទទួលបានពីការបោះផ្សាយភាគហ៊ុន | 2,176,400 | - |
| បង់ភាគលាភ | (349,000) | - |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន | 50,459,279 | 6,027,803 |
| **ការ កើនឡើង/(ថយចុះ) នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 6,046,040 | (6,483,879) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | 18,300,299 | 24,784,178 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 24,346,339 | 18,300,299 |

**សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមាន:**

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ- (កំណត់សំគាល់ 4 ) | 474,214 | 322,678 |
| ប្រាក់បញ្ញើ និង ប្រាក់តម្កល់នៅតាមធនាគារ នានា (មានកាលកំណត់ 3 ខែឬតិចជាង) (កំណត់សំគាល់ 5) | 23,872,125 | 17,977,621 |
| | 24,346,339 | 18,300,299 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 1. រចនាសម្ព័ន្ធ និងសកម្មភាពចំបង

ធនាគារភូមិ (ខេមបូឌា) អិលធីឌី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលមានអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co. 1413/02E ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

ក្រុមហ៊ុនគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបាន និងកំពុងបន្តសកម្មភាពចំបងជាស្ថាប័នផ្តល់ឥណទានដល់ប្រជាជននៅតាមជនបទក្នុង 31 តំបន់ ដែលមានសាខាចំបងចំនួន 13 និងស្នាក់ការកណ្តាលនៅភ្នំពេញ ។ គោលដៅចំបងរបស់ក្រុមហ៊ុនគឺផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងអាចទទួលយកបានដល់សហគ្រិនខ្នាតតូចនៅតាមជនបទ និងបរិវេណជុំវិញទីក្រុងភ្នំពេញ។

ក្នុងបណ្តាខេត្តក្រុងចំនួន 24 នៅក្នុងប្រទេសកម្ពុជាធនាគារភូមិមានប្រតិបត្តិការនៅ 16 ខេត្ត មានដូចជា បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ក្រចេះ កែប ឧត្តរមានជ័យ ភ្នំពេញ ព្រៃវែង សៀមរាប ស្វាយរៀង និង តាកែវ។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណរយៈពេល 3 ឆ្នាំដើម្បីធ្វើអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់ពីថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2003 ដល់ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2006 ពីធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី 20 ខែ មករា ឆ្នាំ 2006 ធនាគារជាតិនៃកម្ពុជាបានបន្តអាជ្ញាប័ណ្ណនេះសំរាប់រយៈពេល 3 ឆ្នាំទៀតចាប់ពី ថ្ងៃទី 12 ខែ កុម្ភៈ 2006 ដល់ថ្ងៃទី 12 ខែ កុម្ភៈ 2009។ នៅថ្ងៃទី 14 ខែ មករា 2009 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា។

ទីស្នាក់ការចុះបញ្ជីមានទីតាំងនៅផ្ទះលេខ 94 ផ្លូវ 360 សង្កាត់បឹងកេងកង 3 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ក្រុមហ៊ុនមានបុគ្គលិកចំនួន 545 នាក់ (31 ធ្នូ 2010 មានបុគ្គលិក ចំនួន 457 នាក់)

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានអនុញ្ញាតិ និងសំរេចអនុម័តដោយក្រុមប្រឹក្សាភិបាលនៅ ថ្ងៃទី 29 ខែ មីនា ឆ្នាំ 2012 ។

## ធនាគារគូមិ (ខេមបូឌា) អិលធីឌី

### កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

### 2. មូលដ្ឋាននៃការរៀបចំ (ត)

#### (ខ) គោលការណ៍នៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

#### (គ) រូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួនបីគឺ ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់រៀល ជារូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុនដោយសារប្រតិបត្តិការឥណទានរបស់ក្រុមហ៊ុនភាគច្រើនជាប្រាក់រៀល។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀលត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ ទ្រព្យសកម្ម និង បំណុលដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់រៀលនាថ្ងៃតារាងតុល្យការ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រានាថ្ងៃនោះ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

#### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យប៉ាន់ស្មាន និង សន្មតដែលប៉ះពាល់ដល់ការអនុវត្តន៍នូវគោលការណ៍គណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និង ចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និង ការសន្មតត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែនូវគណនីប៉ាន់ស្មានត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះ ត្រូវបានត្រួតពិនិត្យឡើងវិញ និងក្នុងអំឡុងពេលដែលផលប៉ះពាល់នោះនឹងកើតមានឡើងនាពេលអនាគត ។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះត្រូវបានយកមកអនុវត្តដូចគ្នានៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញលើកលែងតែចំណុចដែលបានបញ្ជាក់ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និង បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ឥណទាន ប្រាក់បញ្ញើ ទ្រព្យសកម្មផ្សេងៗ ប្រាក់កម្ចី និងបំណុលផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និង ការវាយតម្លៃនូវសមាសធាតុទាំងនេះត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

### (ខ) មូលដ្ឋាននៃការប្រមូលផ្តុំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និង សាខាតាមខេត្តនានាបន្ទាប់ពីការលុបបំបាត់ចោលនូវសមតុល្យ និងប្រតិបត្តិការអន្តរសាខា ។

### (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និង សាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើតាមតម្រូវការ និង ការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេល 3 ខែ ឬតិចជាងនេះចាប់ពីពេលទិញ និង ដែលអាចប្តូរជាសាច់ប្រាក់បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

### (ឃ) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

### (ង) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ដោយដកចេញនូវចំនួនទាំងឡាយណាដែលបានលុបចោល សំវិធានធនជាក់លាក់ និង សំវិធានធនទូទៅ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) សំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុលោមទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់លើឥណទានអាក្រក់ និង ជាប់សង្ស័យត្រូវបានធ្វើទៅលើឥណទានដែលបានចាត់ទុកថាមិនដំណើរការដែលត្រូវធ្វើបានឡើងដូចខាងក្រោម:

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ): | | |
| ឥណទានក្រោមស្តង់ដារ | ពី 30 ទៅ 59 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 60 ទៅ 89 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | ចាប់ពី 90 ថ្ងៃឡើងទៅ | 100% |
| ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ): | | |
| ឥណទានក្រោមស្តង់ដារ | ពី 30 ទៅ 179 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 180 ទៅ 359 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | ចាប់ពីពី 360 ថ្ងៃឡើងទៅ | 100% |

សំវិធានធនជាក់លាក់ត្រូវបានគណនាតាមភាគរយនៃឥណទានមិនទាន់សងនាចុងការិយបរិច្ឆេទហើយត្រូវបានកត់ត្រាជាចំណាយក្នុងរបាយការណ៍លទ្ធផល ។

ក្រុមហ៊ុនកត់ត្រាសំវិធានធន 100% សំរាប់ឥណទានដែលហួសកាលកំណត់សងលើសពី 30 ថ្ងៃ ។ ចំនួនសំវិធានធនដែលលើសកំរិតតម្រូវដោយធនាគារជាតិកម្ពុជាត្រូវបានបង្ហាញជាសំវិធានធនទូទៅ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និង ជាប់សង្ស័យត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងជារៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំវិធានធនលើ ឥណទានអាក្រក់ និង ជាប់សង្ស័យដូចជា ទំហំនៃឥណទាន បទពិសោធន៍នៃការខាតបង់កន្លងទៅ លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗ ដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងដំណើរការនៃឥណទានក្នុងកំឡុងពេលនៃកិច្ចសន្យា ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011**

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) សំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ (ត)

ឥណទានត្រូវបានលុបបំបាត់ចោលបន្ទាប់ពីគណៈគ្រប់គ្រងវិនិច្ឆ័យឃើញថាពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ ។ ឥណទានដែលបានលុបចោល ត្រូវបានកាត់ចេញពីឥណទានដែលនៅសល់ និងពីសំវិធានធនសំរាប់ឥណទានបាត់បង់ ។

ការប្រមូលបានមកវិញនូវឥណទានដែលបានលុបបំបាត់ចោលពីពេលមុន ត្រូវបានកត់ជាចំណូលប្រតិបត្តិការផ្សេងៗនៅក្នុងរបាយការណ៍លទ្ធផល ។

### (ឆ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ត្រូវបានរក្សាទុកនៅធនាគារជាតិ ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ក្រុមហ៊ុន និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

### (ជ) គណនីត្រូវទទួលផ្សេងៗ

គណនីត្រូវទទួលផ្សេងៗ ត្រូវបានកត់ត្រាទៅតាមតម្លៃដែលបានរំពឹងថានឹងទទួលបាន ។

### (ឈ) អចលនទ្រព្យ និងទ្រព្យសម្ភារ

(i) អចលនទ្រព្យ និង ទ្រព្យសម្ភារ ត្រូវបានកត់ត្រាតាមតម្លៃដើមដកនូវរំលស់បង្គរ និងការខាតបង់នៃឱនភាពតម្លៃបង្គរប្រសិនបើមាន ។ នៅពេលដែលធាតុនៃអចលនទ្រព្យ និងទ្រព្យសម្ភាររួមបញ្ចូលនូវសមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា អចលនទ្រព្យ និងទ្រព្យសម្ភារទាំងនោះ ត្រូវបានចាត់ទុកជាធាតុផ្សេងៗគ្នានៃអចលនទ្រព្យ និងទ្រព្យសម្ភារ ។

រំលស់ត្រូវបានគណនាដោយផ្អែកលើចំនួនដែលអាចរំលស់បាន ដែលជាថ្លៃដើមអចលនទ្រព្យ ឬ ក៏ចំនួនផ្សេងទៀតដែលចាត់ទុកជាថ្លៃដើម ហើយដកចេញនូវនូវតម្លៃដែលនៅសល់ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) អចលនទ្រព្យ និងទ្រព្យសម្ភារ (ត)

រំលស់ត្រូវបានបញ្ចូលជាចំណាយនៅក្នុងនៅក្នុងរបាយការណ៍លទ្ធផល ផ្អែកលើមូលដ្ឋានរំលស់ថយចុះជាលំដាប់ ដោយប្រើតម្លៃយោងនៃទ្រព្យសកម្មនីមួយៗនាដើមការិយបរិច្ឆេទ ផ្អែកតាមអត្រាដូចខាងក្រោម:

| | |
|---|---|
| គ្រឿងសង្ហារឹម និង សម្ភារការិយាល័យ | 25% |
| យានយន្ត | 25% |
| កុំព្យូទ័រ | 50% |

ប្រសិនបើមានការគូសបញ្ជាក់ណាមួយអោយដឹងថា មានការផ្លាស់ប្តូរជាសារវ័ន្តនូវអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់របស់អចលនទ្រព្យ រំលស់អចលនទ្រព្យនោះត្រូវកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

(ii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃអចលនទ្រព្យ និងទ្រព្យសម្ភារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្មនៅពេលដែលទ្រព្យសកម្មនេះ មានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀតត្រូវបានទទួលស្គាល់ជាបន្ទុកចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iii) ចំណេញ ឬខាតពីការបោះបោល ឬការលក់ចេញនៃអចលនទ្រព្យ និងទ្រព្យសម្ភារណាមួយត្រូវបានកំណត់ ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃអចលនទ្រព្យ និង ទ្រព្យសម្ភារទាំងនោះហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃបោះបោល ឬ លក់ចេញ។

### (ញ) ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានកំណត់ដោយតម្លៃដើមដករំលស់បង្គរ និង ឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។ រំលស់ត្រូវបានគណនាផ្អែកលើមូលដ្ឋានរំលស់ថយចុះជាលំដាប់ ផ្អែកតាមអាត្រា 50% ក្នុងមួយឆ្នាំ ។ ប្រសិនបើមានការគូសបញ្ជាក់ណាមួយអោយដឹងថា មានការផ្លាស់ប្តូរជាសារវ័ន្តនូវអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់របស់ទ្រព្យសកម្មអរូបិយ រំលស់ទ្រព្យសកម្មអរូបិយនោះត្រូវកំណត់ឡើងវិញដើម្បី ឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

## ធនាគារភូមិ (ខេមបូឌា) អិលធីឌី

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ជ) ឱនភាពនៃតម្លៃ

*(i) ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថាឱនភាពអាចកើតមានឡើង ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវចាត់ទុកថាមានឱនភាពក្នុងករណីដែលអាចបង្ហាញថាមានហេតុការណ៍មួយ ឬច្រើនជះឥទ្ធិពលអវិជ្ជមានទៅលើចលនាសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មនោះ ។ ករណីនេះមិនត្រូវបានប្រើប្រាស់សំរាប់ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកក្នុងកំណត់សំគាល់ 3 (ច) នោះទេ ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុសំខាន់ៗ ត្រូវបានត្រួតពិនិត្យចំពោះឱនភាពនៃតម្លៃតាមមូលដ្ឋានទ្រព្យសកម្មនីមួយៗ ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលនៅសល់ត្រូវបានវាយតម្លៃជារួមសំរាប់ទ្រព្យសកម្មដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវដកចេញប្រសិនបើការដកចេញអាចពាក់ព័ន្ធជាមួយនឹងព្រឹត្តការណ៍ ដែលកើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់លើឱនភាព ។

*(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ដើម្បីកំណត់ថាតើមានកត្តាដែលនាំឱ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើង ការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មឬឯកតាបង្កើតសាច់ប្រាក់គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់និងតម្លៃទីផ្សារដកចំណាយលក់ចេញ ។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្នដោយប្រើប្រាស់អត្រាការប្រាក់មុនដកពន្ធ ដែលឆ្លុះបញ្ចាំងតម្លៃទីផ្សារផ្អែកលើតម្លៃនៃពេលវេលានិងហានិភ័យជាក់លាក់សំរាប់ទ្រព្យសកម្មទាំងនោះ ។ សំរាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាទៅក្រុមតូចៗនៃទ្រព្យសកម្មដែលអាចបង្កើតសាច់ប្រាក់ពីការបន្តប្រើប្រាស់ដែលមិនពឹងផ្អែកខ្លាំងលើលំហូរចូលនៃសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ("ឯកតាបង្កើតសាច់ប្រាក់") ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ឱនភាពនៃតម្លៃ (ត)

*(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)*

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់ពីឱនភាពនៃតម្លៃត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

### (ឋ) ប្រាក់បញ្ញើរបស់អតិថិជន

ប្រាក់បញ្ញើរបស់អតិថិជនត្រូវបានកត់ត្រាតាមតម្លៃនៃប្រាក់តម្កល់ ។

### (ឌ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើម ដែលមិនទាន់បានទូទាត់ ។ សោហ៊ុយផ្សេងៗ ដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានធ្វើមូលធនកម្ម និង ធ្វើរំលស់ទៅតាមរយៈពេលរបស់ប្រាក់កម្ចីនោះដោយប្រើវិធីសាស្ត្ររំលស់ថេរ ។

### (ឍ) សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬ កិច្ចសន្យាដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន ហើយអាចប៉ាន់ស្មានដោយភាពជឿជាក់ថានឹងមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវ័ន្ត សំវិធានធនត្រូវបានកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ ដែលរំពឹងទុកនាពេលអនាគតតាមអត្រាមុនបង់ពន្ធដែលវាឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃរូបិយប័ណ្ណ និង ដោយសមស្របទៅនឹងហានិភ័យជាក់លាក់ចំពោះបំណុល ។

### (ណ) ទុនបំរុង

ទុនបំរុងតំណាងឱ្យប្រាក់ចំណេញដែលបានផ្ទេរពីកម្មវិធីធនាគារភូមិ ។ ប្រាក់ចំណេញសុទ្ធចំនួន 5% បន្ទាប់ពីការដកការខាតបង់ពីគ្រាមុនត្រូវបានផ្ទេរទៅទុនបំរុង។ បន្ទាប់ពីធនាគារជាតិនៃកម្ពុជាផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដល់ក្រុមហ៊ុន នៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 មក ការផ្ទេរនេះបានផ្អាកនៅពេលទុនបំរុងស្មើនឹង 10% នៃដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុន ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ណ) ទុនបំរុង (ត)

ចាប់ពីថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ក្រុមហ៊ុនត្រូវបានតម្រូវឲ្យបង្កើតទុនបំរុងដោយម្ចាស់កម្ចី Instituto de Credito Oficial ("ICO") ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងខ្ចីឥណទាន ។

ទុនបំរុងនេះត្រូវបានផ្ទេរពីប្រាក់ចំណេញរក្សាទុកចំនួន 3.5% នៃប្រាក់កម្ចីមិនទាន់ទូទាត់សងឲ្យ Instituto de Credito Oficial ("ICO") នៅរៀងរាល់ចុងឆ្នាំ រហូតដល់ថ្ងៃ ទី 31 ខែ ធ្នូ ឆ្នាំ 2021 ។

### (ត) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬ ដោយប្រយោល ឬ មានឥទ្ធិពលជាខ្លាំងទៅលើភាគីមួយទៀត ក្នុងការធ្វើសេចក្តីសំរេច ហិរញ្ញវត្ថុ និង ប្រតិបត្តិការ ឬ ផ្ទុយមកវិញ បើក្រុមហ៊ុន និង ភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬ ក៏មាន ឥទ្ធិពលជាខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល និង រួមបញ្ចូលនូវរូបវន្តបុគ្គលនៃសមាជិកគ្រួសារដែលជិតស្និទ្ធក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិផងដែរ។

តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិយមន័យរបស់សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវភាគីដែលកាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុនក្រុមហ៊ុន ឬនៃសិទ្ធិបោះឆ្នោត និងរាប់បញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់ដែលរួមចំណែកក្នុងការអភិបាល ការដឹកនាំ ការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តន៍នៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

### (ថ) ការទទួលស្គាល់ប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានមួយក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាការប្រាក់ថាជាចំណូលត្រូវបានព្យួរទុក ហើយត្រូវទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ ។ ចំណូលពីការប្រាក់ត្រូវបានធ្វើការគណនាដោយប្រើវិធីសាស្ត្រសមតុល្យថយចុះលើសមតុល្យឥណទានដែលនៅសល់ប្រចាំខែ ។

ចំណាយត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

### (ទ) ជំនួយ

ជំនួយដែលទទួលបាន ដើម្បីជួយទៅលើប្រតិបត្តិការទាំងឡាយរបស់ក្រុមហ៊ុនត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល ផ្អែកតាមមូលដ្ឋានជាប្រព័ន្ធនិងសមស្របដោយផ្គូរផ្គងជាមួយនឹងចំណាយដែលត្រូវទូទាត់។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ទ) ជំនួយ (ត)

ជំនួយដែលទទួលបានសំរាប់ការទិញអចលនទ្រព្យ និង ទ្រព្យសម្ភារ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល ផ្អែកតាមមូលដ្ឋានជាប្រព័ន្ធទៅតាមអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសកម្ម ។ ជំនួយដែលមិនទាន់បានបញ្ចូលទៅជាចំណេញ ឬខាតត្រូវបានបង្ហាញជាជំនួយពន្យារ។

#### (ធ) ភតិសន្យាប្រតិបត្តិ

រាល់ភតិសន្យាទាំងឡាយដែលហានិភ័យ និង លាភការនៃម្ចាស់កម្មសិទ្ធិរបស់ទព្យសកម្មស្ថិតនៅជាមួយនឹងម្ចាស់ទ្រព្យត្រូវបានទទួលស្គាល់ជាភតិសន្យាប្រតិបត្តិការ។ ថ្លៃឈ្នួលក្នុងបែបផែនជាភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល តាមវិធីសាស្រ្តរំលស់ថេរទៅតាមថេរវេលានៃការជួល។ ការជួលមិនត្រូវបានទទួលជាបំណុលទេលុះត្រាកាតព្វកិច្ចក្នុងការបង់ត្រូវបានដល់កាលកំណត់ ។

#### (ន) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ ឬ ខាតប្រចាំឆ្នាំរួមមាន ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ។ ក្នុងករណីនេះវាក៏ត្រូវបានកំណត់បង្ហាញថាជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុនផងដែរ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំគឺជាពន្ធដែលរំពឹងទុកថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬ បានអនុម័តជាអាទ៍នៅថ្ងៃតារាងតុល្យការជាមួយនឹង និយ័តកម្ម ណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារត្រូវបានកំណត់តាមវិធីសាស្រ្តតារាងតុល្យការ លើភាពលំអៀងជាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ។ តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះគឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬ ការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតុល្យការ ។

ពន្ធពន្យារលើទ្រព្យសកម្មត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារលើទ្រព្យសកម្មនេះ ត្រូវបានកាត់បន្ថយក្នុងករណីដែលមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (យ) ស្តង់ដារ និងការបកស្រាយថ្មី ដែលនឹងត្រូវអនុវត្តនាពេលអនាគត (ត)

ដូចមានចែងក្នុងប្រកាសលេខ 068 សហវ-ប្រក ចុះថ្ងៃទី 8 ខែ មករា ឆ្នាំ 2009 ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រុមប្រឹក្សាជាតិគណនេយ្យនៃកម្ពុជាបានអនុម័តឲ្យប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ដែលមានប្រសិទ្ធភាពអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុសំរាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2012 ។ ស្តង់ដារថ្មីនេះនឹងត្រូវបានកំណត់ជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ស្តង់ដារខាងក្រោមនេះគឺត្រូវបានរំពឹងទុកថានឹងមានផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ៖

- **ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា 1 ស្តីពីការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ បានបញ្ចូលនូវ** វាក្យសព្ទចំណូលសរុប ដែលបង្ហាញនូវបំរែបំរួលមូលធនក្នុងការិយបរិច្ឆេទក្រៅពីការប្រែប្រួល ដែលបណ្តាលមកពីប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនក្នុងសមត្ថភាពជាម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន។ ចំណូលសរុបនេះ អាចបង្ហាញនៅក្នុងរបាយការណ៍ចំណូលសរុបតែមួយ (ដោយរួមបញ្ចូលគ្នារវាងរបាយការណ៍លទ្ធផល និងរាល់ការប្រែប្រួលមូលធនដែលមិនពាក់ព័ន្ធនឹងម្ចាស់ហ៊ុនក្នុងរបាយការណ៍តែមួយ) ឬ ក៏បង្ហាញនៅក្នុងរបាយការណ៍លទ្ធផល និង របាយការណ៍ចំណូលសរុប ផ្សេងពីគ្នា។
- **ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា 23 ស្តីពីបន្ទុកប្រាក់កម្ចី** មិនអនុញ្ញាតឲ្យទទួលស្គាល់បន្ទុកប្រាក់កម្ចីជាចំណាយ ហើយតម្រូវឲ្យក្រុមហ៊ុនធ្វើមូលធនកម្ម បន្ទុកប្រាក់កម្ចីណាដែលចូលរួមដោយផ្ទាល់ក្នុងការទិញសាងសង់ ឬ ផលិតនូវទ្រព្យសកម្មដែលកំពុងដំណើរការឲ្យក្លាយទៅជាថ្លៃ ដើមរបស់ទ្រព្យសកម្មនោះ។
- **ការចាត់ថ្នាក់ឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ** (**ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា 39 ស្តីពីឧបករណ៍ហិរញ្ញវត្ថុ**: ការទទួលស្គាល់ និងការវាស់វែង និង**ស្តង់ដាររបាយការណ៍អន្តរជាតិនៃកម្ពុជា 7 ស្តីពីឧបករណ៍ហិរញ្ញវត្ថុ: ការបង្ហាញ**) អនុញ្ញាតឲ្យក្រុមហ៊ុនចាត់ថ្នាក់ឡើងវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជាឧបករណ៍ derivatives (លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុដែលទទួលស្គាល់ដំបូង តាមតម្លៃទីផ្សារ តាមរយៈចំណេញ ឬខាត) ចេញពីទ្រព្យសកម្មហិរញ្ញវត្ថុដែលទទួលស្គាល់តាមតម្លៃ ទីផ្សារតាមរយៈចំណេញ ឬ ខាតក្នុងកាលៈទេសៈពិសេសណាមួយ។ ការធ្វើវិសោធនកម្មនេះក៏អនុញ្ញាតឲ្យក្រុមហ៊ុនធ្វើការផ្ទេរពីក្រុមទ្រព្យសកម្មហិរញ្ញវត្ថុសំរាប់លក់ទៅជាឥណទាន និងគណនីត្រូវទទួលសំរាប់ទ្រព្យសកម្មហិរញ្ញវត្ថុណាដែលបំពេញនូវនិយមន័យរបស់ឥណទាន និង គណនីត្រូវទទួលហើយប្រសិនបើក្រុមហ៊ុនមានបំណង និង លទ្ធភាពរក្សាទ្រព្យសកម្មហិរញ្ញវត្ថុនេះរហូតដល់ពេលរំពឹងទុកណាមួយ ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ស្តង់ដារ និងការបកស្រាយថ្មី ដែលនឹងត្រូវអនុវត្តនាពេលអនាគត (ត)

- **ស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (CIAS) 39 ស្តីពីឧបករណ៍ហិរញ្ញវត្ថុ: ការទទួលស្គាល់ និងការវាស់វែង** បង្កើតនូវគោលការណ៍សំរាប់ការទទួលស្គាល់ និងវាស់វែងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាមួយចំនួនទាក់ទងនឹងការទិញ ឬ លក់ឧបករណ៍មិនមែនហិរញ្ញវត្ថុមួយចំនួន។ ការអនុវត្តនូវ CIAS 39 នឹងធ្វើឲ្យមានការកែប្រែនូវគោលនយោបាយគណនេយ្យ ទៅលើឧបករណ៍ហិរញ្ញវត្ថុ ៖

  **ឥណទានផ្តល់ដល់អតិថិជន:** បច្ចុប្បន្ននេះឥណទានផ្តល់ដល់អតិថិជន ត្រូវបានដាក់បង្ហាញក្នុងតារាងតុល្យការតាមថ្លៃដើមដែលនៅសល់ដោយដកចេញចំនួនទាំងឡាយណាដែលបានលុបចោលសំវិធានធនជាក់លាក់ និង សំវិធានធនទូទៅ ។ ដោយឡែកក្រោម CIAS 39 ទ្រព្យសកម្មបែបនេះត្រូវបានទទួលស្គាល់ជាបឋមតាមតម្លៃទីផ្សារ រួមបញ្ចូលទាំងចំណាយប្រតិបត្តិការផ្សេងៗ។ ក្រោយពីការទទួលស្គាល់បឋមមក គណនីឥណទាន និងគណនីអតិថិជនត្រូវបានវាស់វែងតាមការរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រ អត្រាការប្រាក់ប្រសិទ្ធភាព ដោយដកចេញនូវការខាតបង់លើឱនភាពនៃតម្លៃ ។

  **ការថយចុះនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ:** បច្ចុប្បន្ននេះ ក្រុមហ៊ុនអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទាន និង សំវិធានធន ដែលតម្រូវដោយប្រកាសលេខ ធ7-02-186 ប្រ.ក. ចុះថ្ងៃទី 13 ខែ កញ្ញា ឆ្នាំ 2002 ចេញដោយធនាគារជាតិនៃកម្ពុជា ។ CIAS 39 តម្រូវឲ្យក្រុមហ៊ុនវាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ទាំងតាមមូលដ្ឋាននៃការវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុទោល និង តាមមូលដ្ឋាននៃការវាយតម្លៃជាក្រុម ដើម្បីរកមើលថាតើមានភស្តុតាងណាមួយបង្ហាញថាមានការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទោល និងទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមដែរឬទេ។ ការខាតបង់ បណ្តាលមកពីការថយចុះតម្លៃត្រូវបានវាស់វែងដោយភាពលំអៀង រវាងតម្លៃកត់ត្រាក្នុងបញ្ជីនៃទ្រព្យសកម្មមួយធៀបនឹងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត ដោយធ្វើអប្បហារផ្អែកលើអត្រាការប្រាក់ដើមរបស់ទ្រព្យសកម្មនោះ ។ ការខាតបង់ត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬ ខាត និង បង្ហាញនៅក្នុងគណនីសំវិធានធន ជាមួយនឹងឥណទាន និងគណនីអតិថិជន។ នៅពេលដែលមានព្រឹត្តិការណ៍មួយកើតឡើង បន្ទាប់ពីការទទួលស្គាល់ការខាតបង់លើការថយតម្លៃរបស់ឥណទាន ដែលព្រឹត្តិការណ៍នេះធ្វើឲ្យចំនួនខាតបង់ពីការថយតម្លៃរបស់ឥណទានថយចុះចំនួន ការថយចុះនៃការខាតបង់ពីការថយតម្លៃរបស់ឥណទាន នឹងត្រូវបង្វែរមកវិញតាមរយៈចំណេញ ឬខាត ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ស្តង់ដារ និងការបកស្រាយថ្មី ដែលនឹងត្រូវអនុវត្តនាពេលអនាគត (ត)

**ប្រាក់បញ្ញើពីអតិថិជន:** បច្ចុប្បន្ននេះក្រុមហ៊ុនវាស់វែងប្រាក់បញ្ញើពីអតិថិជនដោយយោងទៅតាមតម្លៃនៃប្រាក់តម្កល់។ CIAS 39 បំណុលនេះត្រូវបានទទួលស្គាល់ជាបឋមតាមតម្លៃទីផ្សារដោយដកនូវតម្លៃប្រតិបត្តិការផ្សេងៗ។ ក្រោយពីការទទួលស្គាល់បឋមមក បំណុលហិរញ្ញវត្ថុទាំងនេះត្រូវបានវាស់វែងតាមការរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

**ចំណូលការប្រាក់ និង ចំណាយការប្រាក់:** បច្ចុប្បន្ននេះ ក្រុមហ៊ុនកត់ត្រាចំណូល និងចំណាយ ការប្រាក់តាមមូលដ្ឋានបង្គរទៅតាមអត្រាក្នុងកិច្ចសន្យាលើកលែងតែមានករណីសង្ស័យជាក់លាក់ណាមួយលើលទ្ធភាពនៃការប្រមូលត្រលប់វិញ ក្នុងករណីនេះការប្រាក់ត្រូវបានព្យួរទុក រហូតដល់ពេលដែលគេទទួលបានសាច់ប្រាក់ជាក់ស្តែង។ CIAS 39 តម្រូវឲ្យកត់ត្រាចំណូល និង ចំណាយការប្រាក់នៃរាល់ឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់ទាំងអស់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។ ទាក់ទិនទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុណាមួយ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម ដែលមានលក្ខណៈស្រដៀងគ្នា ហើយបានថយចុះតម្លៃចំណូលការប្រាក់ត្រូវបានគណនាតាម អត្រាការប្រាក់ដែលបានប្រើក្នុងការគណនាបច្ចុប្បន្ន ដោយប្រើលំហូរសាច់ប្រាក់នាពេលអនាគតដើម្បីធ្វើការវាស់វែងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ។

## 4. សាច់ប្រាក់ក្នុងដៃ

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| ទីស្នាក់ការកណ្តាល | 2,000 | 2,000 |
| សាខា | 472,214 | 320,678 |
| | 474,214 | 322,678 |

ចំនួនខាងលើត្រូវបានធ្វើការវិភាគតាមរូបិយប័ណ្ណដូចខាងក្រោម:

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| ប្រាក់រៀលខ្មែរ | 261,983 | 182,654 |
| ប្រាក់ដុល្លារអាមេរិក | 187,891 | 130,798 |
| ប្រាក់បាតថៃ | 24,340 | 9,226 |
| | 474,214 | 322,678 |

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011

## 5. ប្រាក់បញ្ញើ និង តម្កល់នៅធនាគារនានា

| | 2011<br>ពាន់រៀល | 2010<br>ពាន់រៀល |
|---|---|---|
| *គណនីចរន្ត* | | |
| ធនាគារជាតិនៃកម្ពុជា | 12,464,640 | 42,194 |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | 194,159 | 8,523,806 |
| ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 321,831 | - |
| ធនាគារម៉ារូហានជប៉ុន ភីអិលស៊ី | 101,439 | - |
| *គណនីសន្សំ* | | |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | 3,101,882 | 1,990,429 |
| ធនាគារអភិវឌ្ឍជនបទកម្ពុជា | 513 | 588 |
| *ប្រាក់បញ្ញើមានកាលកំណត់* | | |
| ធនាគារជាតិនៃកម្ពុជា * | 6,583,570 | 6,606,390 |
